**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :**......៩៨០......**ក.ប**/ប្រ.ក.ប.ស.ស

# ប្រកាស
# ស្តីពី
# ការកែសម្រួលប្រការ៦ ប្រការ១១ និងប្រការ១៣ នៃប្រកាសលេខ ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ/បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៤ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៤ ២៧ ៦៩

## សម្រេច

**ប្រការមួយ.-**

ប្រការ៦ ប្រការ១១ និងប្រការ១៣ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីតាវកាលិកហានិភ័យការងារ ត្រូវបានកែសម្រួលដូចតទៅ៖

**ប្រការ ៦ថ្មី.-**

៦.១ ប្រាក់ឈ្នួលមធ្យម គឺជាផលចែកមធ្យមភាគនៃប្រាក់ឈ្នួលជាប់ភាគទានក្នុងរយៈពេលជាក់ស្ដែងមិនលើស ០៦(ប្រាំមួយ)ខែ មុនខែបរិច្ឆេទនៃគ្រោះថ្នាក់។ ប្រាក់ឈ្នួលជាប់ភាគទាន ត្រូវបានកំណត់ក្នុងតារាងដូចមានចែងក្នុងឧបសម្ព័ន្ធ១ នៃប្រកាសនេះ។

៦.២ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាផលចែក នៃប្រាក់ឈ្នួលមធ្យមដូចមានចែងក្នុងចំណុច ៦.១ នឹង៣០(សាមសិប)ថ្ងៃ។

៦.៣ ការគណនាប្រាក់ឈ្នួលមធ្យម ដែលកំណត់នៅក្នុងប្រកាសនេះមានអានុភាពចំពោះតែការគណនាតាវកាលិកសន្តិសុខសង្គម ប៉ុណ្ណោះ។

**ប្រការ ១១ថ្មី.-**

១១.១ ឧត្តរជីវី នៃជនរងគ្រោះដោយហានិភ័យការងារ ដូចមានចែងក្នុងមាត្រា៣៤នៃអនុក្រឹត្យលេខ ១៦អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមមានសិទ្ធិទទួលបានតាវកាលិកឧត្តរជីវី។

១១.២ តាវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្ដល់ឱ្យសិទ្ធិវន្តនៃជនរងគ្រោះតាមអត្រាដូចខាងក្រោម៖

ក. ក្នុងករណីសិទ្ធិវន្ត មានរួមទាំងប្រពន្ធ ឬប្ដី កូន និងឪពុកម្ដាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក
- ប្រពន្ធ ឬប្ដី =៣/៥x៦៣%បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក=២/៥x៦៣%បឈម
- ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬមនុស្សចាស់ជរា ក្នុងបន្ទុក=៧%បឈម

ខ. ក្នុងករណីសិទ្ធិវន្តមានតែប្រពន្ធ ឬប្ដី និង/ឬកូន
- ប្រពន្ធ ឬប្ដី =៣/៥x៧០%បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក =២/៥x៧០%បឈម

គ. ក្នុងករណីសិទ្ធិវន្តមានតែឪពុកម្ដាយ ឬមនុស្សចាស់ជរា
-ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក =៣៥%បឈម

ឃ. ក្នុងករណីសិទ្ធិវន្តមានតែកូន និងឪពុកម្ដាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក =២៨%បឈម
- ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក =២៨%បឈម

ង. ក្នុងករណីសិទ្ធិវន្តមានតែប្រពន្ធ ឬប្ដី និងឪពុកម្ដាយ ឬមនុស្សចាស់ជរា
- ប្រពន្ធឬប្ដី =២៨%បឈម
- ធនលាភសរុបសម្រាប់ឪពុកម្ដាយឬមនុស្សចាស់ជរាក្នុងបន្ទុក =២៨%បឈម

ច. ក្នុងករណីសិទ្ធិវន្តមានតែប្ដី ឬប្រពន្ធឬកូន ក្នុងបន្ទុក=៥៦%បឈម

**ប្រការ ១៣ថ្មី.-**

១៣.១ ការទាមទារតាវកាលិកសម្រាប់ការថែទាំ និងការព្យាបាលអាចត្រូវបានធ្វើឡើងដោយមូលដ្ឋានសុខាភិបាលដែលព្យាបាលជនរងគ្រោះ ឬនិយោជក ឬក៏កម្មករនិយោជិតជាជនរងគ្រោះផ្ទាល់តាមទម្រង់ "**តាវកាលិកហានិភ័យការងារ**" ដូចមានចែងក្នុងឧបសម្ព័ន្ធ៤ នៃប្រកាសនេះ។

១៣.២ ការទាមទារប្រាក់បំណាច់ថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្ដោះអាសន្នត្រូវធ្វើឡើងដោយជនរងគ្រោះ ឬតំណាងតាមទម្រង់ "**តាវកាលិកហានិភ័យការងារ**" ដូចមានចែងក្នុងឧបសម្ព័ន្ធ៤ នៃប្រកាសនេះ។ បែបបទនៃការទាមទារនេះត្រូវមានភ្ជាប់ជាមួយនូវវេជ្ជបញ្ជា និងលិខិតបញ្ជាក់ពីគ្រូពេទ្យព្យាបាលផ្លូវការ។

១៣.៣ ការទាមទារតាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ត្រូវធ្វើឡើងដោយជនរងគ្រោះតាមទម្រង់ "**តាវកាលិកហានិភ័យការងារ**" ដូចមានចែងក្នុងឧបសម្ព័ន្ធ៤នៃប្រកាសនេះ។ ក្នុងករណីដែលជនរងគ្រោះមិនអាចមានសមត្ថភាពក្នុងការទាមទារតាវកាលិកបាន ដោយសារស្ថានភាពនៃការបាត់បង់សមត្ថភាពការងារធ្ងន់ធ្ងរ ការទាមទារនេះអាចត្រូវធ្វើឡើងដោយអ្នកតំណាងជនរងគ្រោះ។ អ្នកតំណាងជនរងគ្រោះ អាចជាប្ដី ប្រពន្ធ កូន ឬជនដែលមានភារៈថែរក្សាដោយផ្ទាល់ចំពោះជនរងគ្រោះ។

១៣.៤ ការទាមទារតាវកាលិកឧត្តរជីវី និងសោហ៊ុយបូជាសព ត្រូវធ្វើឡើងដោយសិទ្ធិវន្តនៃជនរងគ្រោះ ឬ អ្នកតំណាងតាមទម្រង់ "**តាវកាលិកហានិភ័យការងារ**" ដូចមានចែងក្នុងឧបសម្ព័ន្ធ៤ នៃប្រកាសនេះ។

១៣.៥ សិទ្ធិនៃការទាមទារបំណាច់ប្រចាំថ្ងៃសម្រាប់ហានិភ័យការងារ និងប្រាក់វិភាជន៍បូជាសព ត្រូវអស់សុពលភាពត្រឹមរយៈពេល០១(មួយ)ឆ្នាំ។ ចំពោះសិទ្ធិក្នុងការទាមទារប្រាក់ធនលាភត្រូវអស់សុពលភាពត្រឹមរយៈពេល០៥(ប្រាំ)ឆ្នាំ។

១៣.៦ ការបើកប្រាក់ធនលាភ ត្រូវធ្វើជាប្រចាំខែ។

**ប្រការពីរ.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ក្រុមប្រឹក្សាភិបាល នៃប.ស.ស
  "ដើម្បីជូនជ្រាប"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

*ឧបសម្ព័ន្ធ១ នៃប្រកាសលេខ..២៨០....ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី..១៨..ខែ..តុលា..ឆ្នាំ២០១៨ ស្តីពីការកែសម្រួលប្រការ៦ ប្រការ១១ និងប្រការ១៣ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ*

# តារាងប្រាក់ឈ្នួលជាប់ភាគទាន

| ថ្នាក់ | ចំនួនប្រាក់ឈ្នួលសរុប (រៀល) | ប្រាក់ឈ្នួលជាប់ភាគទាន (រៀល) |
|---|---|---|
| ១ | ២០០ ០០០ ចុះ | ២០០ ០០០ |
| ២ | ២០០ ០០១ - ២៥០ ០០០ | ២២៥ ០០០ |
| ៣ | ២៥០ ០០១ - ៣០០ ០០០ | ២៧៥ ០០០ |
| ៤ | ៣០០ ០០១ - ៣៥០ ០០០ | ៣២៥ ០០០ |
| ៥ | ៣៥០ ០០១ - ៤០០ ០០០ | ៣៧៥ ០០០ |
| ៦ | ៤០០ ០០១ - ៤៥០ ០០០ | ៤២៥ ០០០ |
| ៧ | ៤៥០ ០០១ - ៥០០ ០០០ | ៤៧៥ ០០០ |
| ៨ | ៥០០ ០០១ - ៥៥០ ០០០ | ៥២៥ ០០០ |
| ៩ | ៥៥០ ០០១ - ៦០០ ០០០ | ៥៧៥ ០០០ |
| ១០ | ៦០០ ០០១ -៦៥០ ០០០ | ៦២៥ ០០០ |
| ១១ | ៦៥០ ០០១ - ៧០០ ០០០ | ៦៧៥ ០០០ |
| ១២ | ៧០០ ០០១ - ៧៥០ ០០០ | ៧២៥ ០០០ |
| ១៣ | ៧៥០ ០០១ - ៨០០ ០០០ | ៧៧៥ ០០០ |
| ១៤ | ៨០០ ០០១ - ៨៥០ ០០០ | ៨២៥ ០០០ |
| ១៥ | ៨៥០ ០០១ - ៩០០ ០០០ | ៨៧៥ ០០០ |
| ១៦ | ៩០០ ០០១ - ៩៥០ ០០០ | ៩២៥ ០០០ |
| ១៧ | ៩៥០ ០០១ - ១ ០០០ ០០០ | ៩៧៥ ០០០ |
| ១៨ | ១ ០០០ ០០១ - ១ ០៥០ ០០០ | ១ ០២៥ ០០០ |
| ១៩ | ១ ០៥០ ០០១ - ១ ១០០ ០០០ | ១ ០៧៥ ០០០ |
| ២០ | ១ ១០០ ០០១ - ១ ១៥០ ០០០ | ១ ១២៥ ០០០ |
| ២១ | ១ ១៥០ ០០១ - ១ ២០០ ០០០ | ១ ១៧៥ ០០០ |
| ២២ | ១ ២០០ ០០១ ឡើង | ១ ២០០ ០០០ |

*ឧបសម្ព័ន្ធ៤ នៃប្រកាសលេខ...២៨០.....ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី...១៨..ខែ..តុលា..ឆ្នាំ២០១៨ ស្តីពីការកែសម្រួលប្រការ៦ ប្រការ១១ និងប្រការ១៣ នៃប្រកាសលេខ១០៩ ក.ប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ*

| **សម្រាប់មន្ត្រី ប.ស.ស** | |
|---|---|
| លេខតាវកាលិក | ☐☐☐☐☐ / ☐☐ |
| ហត្ថលេខា | ......./......../........ |

# តាវកាលិកហានិភ័យការងារ

① នាមករណ៍សហគ្រាស៖.............................................. លេខអត្តសញ្ញាណសហគ្រាស៖ ☐☐☐☐☐☐☐☐

លេខទូរស័ព្ទ៖ ☐☐☐☐☐☐☐☐☐☐ ☐☐☐☐☐☐☐☐☐☐ អ៊ីម៉ែលE-Mail:..............................................

② គោត្តនាមនិងនាមកម្មករនិយោជិត៖.............................................. ភេទ៖................

លេខអត្ត.កម្មករនិយោជិត៖ ☐☐☐☐☐☐☐☐☐☐☐☐☐ លេខទូរស័ព្ទ៖ ☐☐☐☐☐☐☐☐☐☐

③ ប្រភេទគ្រោះថ្នាក់: ☐ ធ្វើដំណើរ ☐ កន្លែងធ្វើការ ☐ ជម្ងឺវិជ្ជាជីវៈ គ្រោះថ្នាក់ថ្ងៃខែឆ្នាំ:.........../.........../.............. ម៉ោងគ្រោះថ្នាក់: ☐☐ ☐☐

-មូលហេតុគ្រោះថ្នាក់.............................................. បណ្តាលឲ្យរបួស..............................................

④ ឈ្មោះមន្ទីរពេទ្យ/មន្ទីរពហុព្យាបាល៖ ..............................................

-ចំនួនថ្ងៃសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ/មន្ទីរពហុព្យាបាល៖ ..............ថ្ងៃ ចាប់ពីថ្ងៃខែឆ្នាំ......... /........../............ ដល់ថ្ងៃខែឆ្នាំ......... /........../...........

-ចំនួនថ្ងៃសម្រាកព្យាបាលបន្តនៅផ្ទះ៖ ...............ថ្ងៃ ចាប់ពីថ្ងៃខែឆ្នាំ......... /........../............ ដល់ថ្ងៃខែឆ្នាំ......... /........../............

⑤ **ការទាមទារតាវកាលិកហានិភ័យការងារ**

☐ តាវកាលិកព្យាបាល ☐ តាវកាលិកថែទាំ ☐ តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ☐ តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

☐ តាវកាលិកអ្នកចាំថែរក្សា ☐ ប្រាក់វិភាជន៍បូជាសព ☐ តាវកាលិកឧត្តរជីវី

*** ព័ត៌មានលំអិតសម្រាប់សាមីខ្លួនឬអ្នកតំណាងទាមទារតាវកាលិកផ្នែកហានិភ័យការងារ**

⑥ គោត្តនាមនិងនាមសាមីខ្លួនឬអ្នកតំណាង៖ .............................................. ភេទ៖ .............. ថ្ងៃខែឆ្នាំកំណើត............. /............./...............

អាសយដ្ឋានផ្ទះលេខ..............ផ្លូវលេខ.............. ភូមិ.....................សង្កាត់(ឃុំ)...........................ខណ្ឌ(ស្រុក)..........................រាជធានី(ខេត្ត) ...........................

លេខទូរស័ព្ទ៖ ☐☐☐☐☐☐☐☐☐☐

លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន៖ ☐☐☐☐☐☐☐☐☐☐ ចុះថ្ងៃទី............. /.............../...............

*ខ្ញុំសូមសន្យាថារាល់ព័ត៌មានដែលបានផ្តល់ជូនខាងលើពិតជាត្រឹមត្រូវប្រាកដមែន។*

ថ្ងៃ................................ខែ.....................ឆ្នាំ.......................គ.ស.២៥.......

..................... ថ្ងៃទី........... ខែ............... ឆ្នាំ២០........

**ស្នាមមេដៃស្តាំអ្នកស្នើសុំ**

*** ឯកសារភ្ជាប់៖**

-ឯកសារវេជ្ជសាស្ត្រ-អមវេជ្ជសាស្ត្រ
-វិក្កបត្រចំណាយព្យាបាល
-លិខិតចេញចូលមន្ទីរពេទ្យ/វេជ្ជបញ្ជា
-លិខិតសុំអនុញ្ញាតិច្បាប់
-សេចក្តីចម្លងសំបុត្រកំណើត
-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍
-សេចក្តីចម្លងសំបុត្រមរណភាព
-អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនអ្នកស្នើសុំឬជនរងគ្រោះ